**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ............២១៧............ក.ប/ស.ជ.ព

# សេចក្តីជូនដំណឹង
# ស្តីពី
# ការចូលជាធរមាននៃច្បាប់ស្តីពីសហជីព

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់សហជីព សមាគមនិយោជកគ្រប់ជាន់ថ្នាក់ កម្មករ និយោជិត និងនិយោជកដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បុគ្គលិកធ្វើការតាមផ្លូវអាកាស និងផ្លូវសមុទ្រ ព្រមទាំងសាធារណជនឱ្យបានជ្រាបថា ច្បាប់ស្តីពីសហជីព ត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦។

ដើម្បីធានានូវការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងផ្លូវសមុទ្រ និងធានានូវសិទ្ធិសេរីភាពក្នុងការចរចាជាសមូហភាពរវាងកម្មករ និយោជិត និងនិយោជក ព្រមទាំងជំរុញឱ្យមានសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងរួមចំណែកក្នុងការអភិវឌ្ឍការងារសមរម្យ សំដៅបង្កើនផលិតភាព និងការវិនិយោគដើម្បីបង្កើតការងារថ្មីៗបន្ថែមទៀតជូនដល់ប្រជាពលរដ្ឋ ក្រសួងសូមឱ្យសហជីព និងសមាគមនិយោជកដែលមានបញ្ជិការួច ក៏ដូចជាសហជីព និងសមាគមនិយោជកដែលកំពុងស្នើសុំបញ្ជិកា បំពេញតាមលក្ខខណ្ឌ និងអនុវត្តឱ្យបានត្រឹមត្រូវនូវរាល់កាតព្វកិច្ច ដូចមានចែងក្នុងច្បាប់ស្តីពីសហជីព។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសហជីព សមាគមនិយោជកគ្រប់ជាន់ថ្នាក់ កម្មករ និយោជិត និងនិយោជកដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បុគ្គលិកធ្វើការតាមផ្លូវអាកាស និងផ្លូវសមុទ្រ ព្រមទាំងសាធារណជន ជ្រាបជាព័ត៌មាន និងអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**